# បឹងតាមោក ឬ បឹងកប់ស្រូវ

ការពិត និងតួលេខ #៤៣ ខែមេសា ឆ្នាំ២០២១





អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization • a Cambodian Urban NGO

អង្គការសមាគមធាងត្នោត (STT) ត្រូវបានបង្កើតក្នុងឆ្នាំ២០០៥ និងត្រូវបានចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជួយគាំទ្រដល់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញនៅឆ្នាំ២០០៦។ អង្គការសមាគមធាងត្នោតចាប់ផ្តើមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលផ្តោតលើការជួយលើកកម្ពស់ផ្នែកបច្ចេកទេសដល់សហគមន៍ក្រីក្រ និងបន្ទាប់មកលូតលាស់ខ្លួនដោយផលិតជាផែនទីសហគមន៍ក្រីក្រ ការសិក្សាស្រាវជ្រាវ និងការតស៊ូមតិ ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការជួយដល់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញឱ្យទទួលបានសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន។ អង្គការសមាគមធាងត្នោតសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមក្នុងកិច្ចស្រាវជ្រាវនេះ ជាពិសេសប្រជាពលរដ្ឋមូលដ្ឋានដែលរស់នៅជុំវិញបឹងនេះ។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៥៥៥ ១៩៦៤

អ៊ីម៉ែល៖ info@teangtnaut.org

គេហទំព័រ៖ www.teangtnaut.org ហ្វេសបុក៖ https://www.facebook.com/sttcambodia

ធ្វីទ័រ៖ https://twitter.com/STTCambodia



អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization • a Cambodian Urban NGO

អង្គការសមាគមធាងត្នោត (STT) ត្រូវបានបង្កើតក្នុងឆ្នាំ២០០៥ និងត្រូវបានចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជួយគាំទ្រដល់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញនៅឆ្នាំ២០០៦។ អង្គការសមាគមធាងត្នោតចាប់ផ្តើមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលផ្តោតលើការជួយលើកកម្ពស់ផ្នែកបច្ចេកទេសដល់សហគមន៍ក្រីក្រ និងបន្ទាប់មកលូតលាស់ខ្លួនដោយផលិតជាផែនទីសហគមន៍ក្រីក្រ ការសិក្សាស្រាវជ្រាវ និងការតស៊ូមតិ ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការជួយដល់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញឱ្យទទួលបានសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន។ អង្គការសមាគមធាងត្នោតសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមក្នុងកិច្ចស្រាវជ្រាវនេះ ជាពិសេសប្រជាពលរដ្ឋមូលដ្ឋានដែលរស់នៅជុំវិញបឹងនេះ។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៥៥៥ ១៩៦៤

អ៊ីម៉ែល៖ info@teangtnaut.org

គេហទំព័រ៖ www.teangtnaut.org ហ្វេសបុក៖ https://www.facebook.com/sttcambodia

ធ្វីទ័រ៖ https://twitter.com/STTCambodia



អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization • a Cambodian Urban NGO

អង្គការសមាគមធាងត្នោត (STT) ត្រូវបានបង្កើតក្នុងឆ្នាំ២០០៥ និងត្រូវបានចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជួយគាំទ្រដល់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញនៅឆ្នាំ២០០៦។ អង្គការសមាគមធាងត្នោតចាប់ផ្តើមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលផ្តោតលើការជួយលើកកម្ពស់ផ្នែកបច្ចេកទេសដល់សហគមន៍ក្រីក្រ និងបន្ទាប់មកលូតលាស់ខ្លួនដោយផលិតជាផែនទីសហគមន៍ក្រីក្រ ការសិក្សាស្រាវជ្រាវ និងការតស៊ូមតិ ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការជួយដល់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញឱ្យទទួលបានសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន។ អង្គការសមាគមធាងត្នោតសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមក្នុងកិច្ចស្រាវជ្រាវនេះ ជាពិសេសប្រជាពលរដ្ឋមូលដ្ឋានដែលរស់នៅជុំវិញបឹងនេះ។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៥៥៥ ១៩៦៤

អ៊ីម៉ែល៖ info@teangtnaut.org

គេហទំព័រ៖ www.teangtnaut.org ហ្វេសបុក៖ https://www.facebook.com/sttcambodia

ធ្វីទ័រ៖ https://twitter.com/STTCambodia

# មាតិកា


**មាតិកា** ............ i
**បញ្ជីផែនទី** ............ ii
**ការបដិសេធទទួលខុសត្រូវ** ............ iii
**១. សេចក្តីផ្តើម** ............ ១
**២. ភូមិសាស្ត្រ** ............ ១
**៣. ប្រជាសាស្ត្រ** ............ ២
**៤. សាវតារបឹងតាមោក** ............ ៣
៤.១. ពីចន្លោះឆ្នាំ ១៩៧០ ដល់ ២០១៦ ............ ៣
៤.២. ព្រំប្រទល់បឹងកំណត់ក្នុងឆ្នាំ ២០១៦ ............ ៤
៤.៣. ការសាងសង់ផ្លូវកាត់បឹង ............ ៥
**៥. ពេលវេលានៃការកែសម្រួលផ្ទៃបឹងតាមោក** ............ ៦
៥.១. ផ្ទៃបឹងកែសម្រួលក្នុង ខែតុលា ឆ្នាំ២០១៨ ............ ៦
៥.២. ផ្ទៃបឹងកែសម្រួលក្នុង ខែវិច្ឆិកា ឆ្នាំ២០១៨ ............ ៧
៥.៣. ផ្ទៃបឹងកែសម្រួលក្នុង ខែមេសា ឆ្នាំ២០១៩ ............ ៨
៥.៤. ផ្ទៃបឹងកែសម្រួលក្នុង ខែមីនា ឆ្នាំ២០២០ ............ ៩
៥.៥. ផ្ទៃបឹងកែសម្រួលក្នុង ខែមិថុនា ឆ្នាំ២០២០ ............ ១០
៥.៦. ផ្ទៃបឹងកែសម្រួលក្នុង ខែមិថុនា ឆ្នាំ២០២០ ............ ១១
៥.៧. ផ្ទៃបឹងកែសម្រួលក្នុង ខែកក្កដា ឆ្នាំ២០២០ ............ ១២
៥.៨. ផ្ទៃបឹងកែសម្រួលក្នុង ខែសីហា ឆ្នាំ២០២០ ............ ១៣
៥.៩. ផ្ទៃបឹងកែសម្រួលក្នុង ខែកញ្ញា ឆ្នាំ២០២០ ............ ១៤
៥.១០.ផ្ទៃបឹងកែសម្រួលក្នុង ខែកញ្ញា ឆ្នាំ២០២០ ............ ១៥
៥.១១.ផ្ទៃបឹងកែសម្រួលក្នុង ខែកញ្ញា ឆ្នាំ២០២០ ............ ១៦
៥.១២.ផ្ទៃបឹងកែសម្រួលក្នុង ខែតុលា ឆ្នាំ២០២០ ............ ១៧
៥.១៣.ផ្ទៃបឹងកែសម្រួលក្នុង ខែធ្នូ ឆ្នាំ២០២០ ............ ១៨
៥.១៤.ផ្ទៃបឹងកែសម្រួលក្នុង ខែធ្នូ ឆ្នាំ២០២០ ............ ១៩
៥.១៥.ផ្ទៃបឹងកែសម្រួលក្នុង ខែធ្នូ ឆ្នាំ២០២០ ............ ២០
៥.១៦.ផ្ទៃបឹងកែសម្រួលក្នុង ខែធ្នូ ឆ្នាំ២០២០ ............ ២១
៥.១៧.ផ្ទៃបឹងកែសម្រួលក្នុង ខែមករា ឆ្នាំ២០២១ ............ ២២
**៦. កំហុសបច្ចេកទេស** ............ ២៣
**៧. ការពិភាក្សា** ............ ២៤
ករណីសិក្សា ទី១ – ការភ័យខ្លាចបាត់បង់ដីធ្លី ............ ២៧
ករណីសិក្សា ទី២ –ឱនភាពនៃស្ថានភាពហិរញ្ញវត្ថុរបស់កសិកររស់នៅជុំវិញបឹងតាមោក.... ២៨
ករណីសិក្សា ទី៣ – ជីវិតអ្នកនេសាទលើបឹងតាមោក ............ ២៩
**៨. សេចក្តីសន្និដ្ឋាន** ............ ៣០
**៩. អនុសាសន៍** ............ ៣១

# បញ្ជីផែនទី

ផែនទី ទី១ ៖ ទីតាំងភូមិសាស្ត្រនៃបឹងតាមោក ឬបឹងកប់ស្រូវ.......................................................១
ផែនទី ទី២ ៖ រូបភាពពីផ្កាយរណបហ្គូហ្គល (Google) ខែឧសភា ឆ្នាំ២០១២ និងខែមេសា ឆ្នាំ២០២០....៣
ផែនទី ទី៣ ៖ ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២០ ឆ្នាំ ២០១៦.........................................................៤
ផែនទី ទី៤ ៖ ផ្លូវធំកាត់ចំកណ្ដាលបឹងតាមោក.................................................................................៥
ផែនទី ទី៥ ៖ ទីតាំងដីកាត់ឱ្យលោក ស៊ី ជីនម៉ូវ ក្នុងឆ្នាំ២០១៨....................................................៦
ផែនទី ទី៦ ៖ ទីតាំងដីកាត់ឱ្យសាលារាជធានីភ្នំពេញ ក្នុងឆ្នាំ២០១៨..............................................៧
ផែនទី ទី៧ ៖ ដី ៤៥,៧៩ ហិកតាផ្ដល់ឱ្យឈ្មោះ ស៊ុយ សុផាន និង ដី ៧,៧១ ហិកតាផ្ដល់ឱ្យ
ឈ្មោះ ម៉ែន សុខ...............................................................................................................៨
ផែនទី ទី៨ ៖ ដី ៧៥ ហិកតាផ្ដល់ឱ្យសាលារាជធានីភ្នំពេញ និងដី ៨ហិកតាផ្ដល់ឱ្យនាយកដ្ឋានកណ្ដាល
សន្តិសុខ និងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ.........................................៩
ផែនទី ទី៩ ៖ ដី ១០៤ ៧៥៤ ម៉ែត្រការ៉េកាត់ឱ្យឈ្មោះ ជា សុជាម៉ាដែន..........................................១០
ផែនទី ទី១០ ៖ ដី ២៩៨,៥៥ ហិកតាកាត់ឱ្យក្រសួងការពារជាតិ...................................................១១
ផែនទី ទី១១ ៖ ដី ៣០ ហិកតាកាត់ឱ្យលោកស្រី គឹម ហ៊ាង...........................................................១២
ផែនទី ទី១២ ៖ ដី ៧៤ ៨៥៥ ម៉ែត្រការ៉េ កាត់ឱ្យ ២៣គ្រួសារ.........................................................១៣
ផែនទី ទី១៣ ៖ ដី ១៥,០៣៣ ហិកតា កាត់ឱ្យក្រសួងអភិវឌ្ឍន៍ជនបទ និង ដី ៨,០២ ហិកតាកាត់ឱ្យឈ្មោះ
សេង វុទ្ធី...............................................................................................................១៤
ផែនទី ទី១៤ ៖ ដី១៥ ហិកតាកាត់ឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការសិទ្ធិ
មនុស្សកម្ពុជា និងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការ
ដោយសារមីន.......................................................................................................១៥
ផែនទី ទី១៥ ៖ ដី ៨ ហិកតាកាត់ឱ្យក្រសួងយុត្តិធម៌.................................................................១៦
ផែនទី ទី១៦ ៖ ដី ៧៨ ៣១៤ ម៉ែត្រការ៉េកាត់ឱ្យឈ្មោះ សាយ សោភា.............................................១៧
ផែនទី ទី១៧ ៖ ដី ២០ ហិកតាកាត់ឱ្យឈ្មោះ លន់ ហាក់ និងឈ្មោះ ឈុន ចាន់ធី..............................១៨
ផែនទី ទី១៨ ៖ ដី ២០ ហិកតាកាត់ឱ្យក្រសួងសុខាភិបាល.........................................................១៩
ផែនទី ទី១៩ ៖ ដី ១៩៦,៥៦៥៩ ហិកតាកាត់ឱ្យអ្នកស្រី អ៊ុយ បូរី និងអ្នកស្រី គង់ សុធី....................២០
ផែនទី ទី២០ ៖ ដី ២៧ ៦៥៩ ម៉ែត្រការ៉េកាត់ឱ្យកងរាជអាវុធហត្ថ ១៦ គ្រួសារ..................................២១
ផែនទី ទី២១ ៖ ដី ៤ ហិកតាកាត់ឱ្យក្រសួងមុខងារសាធារណៈ.......................................................២២
ផែនទី ទី ២២ ៖ ផែនទីបង្ហាញទីតាំងកំហុសបច្ចេកទេសពេលប្រើនិយាមការថ្មី................................២៤
ផែនទី ទី ២៣ ៖ ទីតាំងស្តុកទឹកកខ្វក់ក្នុងបឹង.............................................................................២៥
ផែនទី ទី ២៤ ៖ ទីតាំងដីកាន់កាប់ដោយឯកជនធ្វើជាចំការ............................................................២៥
ផែនទី ទី ២៥ ៖ ទីតាំងបង្គោលដាំក្នុងបឹង....................................................................................២៥
ផែនទី ទី ២៦ ៖ ទីតាំងរុក្ខជាតិដែលមានអាយុកាលជាង ២០ឆ្នាំ....................................................២៥
ផែនទី ទី ២៧ ៖ តំបន់បឹងដែលនឹងនៅសេសសល់ក្នុងឆ្នាំ ២០៣៥...............................................៣០

# ការបដិសេធទទួលខុសត្រូវ

របាយការណ៍នេះត្រូវបានរៀបចំ និងចងក្រងឡើងផ្អែកលើអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា និងព័ត៌មានដែលជឿជាក់បានពីប្រជាពលរដ្ឋរស់នៅជុំវិញបឹងតាមោក។ របាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីបឹងតាមោកដែលជាបឹងធំជាងគេបំផុតនៅក្នុងរាជធានីភ្នំពេញ និងបញ្ហាសំខាន់ៗដែលទាមទារការផ្តល់ចំណាប់អារម្មណ៍។ ឯកសារនេះមិនអាចយកប្រើសម្រាប់ដោះស្រាយករណីណាមួយនៅតុលាការឡើយ។

# ១. សេចក្តីផ្តើម

បឹងតាមោក ឬបឹងកប់ស្រូវ គឺជាបឹងធម្មជាតិដ៏ធំជាងគេក្នុងរាជធានីភ្នំពេញ ដែលស្ថិតនៅភាគពាយព្យនៃរាជធានីតាមបណ្តោយមហាវិថីឈ្នះ-ឈ្នះ។ បឹងនេះមានទំហំ ៣ ២៣៩,៧ ហិកតា លាតសន្ធឹងលើខណ្ឌចំនួន ២ សង្កាត់ចំនួន ៦ និងភូមិចំនួន ២៥។ ព្រំប្រទល់បឹងមិនមានការកំណត់ជាផ្លូវការទេ រហូតដល់ឆ្នាំ ២០១៦ ទើបរាជរដ្ឋាភិបាលបានសម្រេចកំណត់ផ្ទៃបឹងតាមោកមានទំហំសរុប ៣ ២៣៩,៧ ហិកតាដាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ប៉ុន្តែក្រោយមកផ្ទៃបឹងនេះត្រូវបានកែសម្រួលយ៉ាងតិច ១៧ដង។ នៅជុំវិញបឹងមានប្រជាជនរស់នៅប្រមាណ ៣០០គ្រួសារ និងមានមនុស្សប្រហែល ១០០០នាក់ ដែលភាគច្រើនប្រកបរបរចិញ្ចឹមជីវិតដោយការនេសាទត្រី ដាំដំណាំ ចិញ្ចឹមត្រី និងរកស៊ីលក់ដូរនៅផ្ទះ។ គ្រួសារទាំងនោះភាគច្រើនរស់ក្នុងលំនៅឋានដែលជាសំណង់មិនរឹងមាំ និងមានសភាពទ្រុឌទ្រោម។ ក្នុងចំណោមនោះគ្រួសារប្រមាណ៣០ភាគរយស្នាក់នៅក្នុងជម្រកបណ្តោះអាសន្ន។ ក្រៅពីជាទីជម្រកសម្រាប់មនុស្ស បឹងតាមោកក៏ជាកន្លែងដែលមានប្រព័ន្ធអេកូដ៏សម្បូរបែប និងចម្រុះរបស់សត្វស្លាប និងសត្វត្រីផងដែរ។

# ២. ភូមិសាស្ត្រ

បឹងតាមោក ឬបឹងកប់ស្រូវ គឺជាបឹងធម្មជាតិដ៏ធំជាងគេក្នុងរាជធានីភ្នំពេញ ដែលមានទំហំផ្ទៃសរុប ៣ ២៣៩,៧ ហិកតា និងបរិមាត្រសរុប ២៩,១ គីឡូម៉ែត្រ។ បឹងនេះស្ថិតនៅភាគពាយព្យនៃរាជធានីភ្នំពេញ លាតសន្ធឹងតាមបណ្តោយមហាវិថីឈ្នះ-ឈ្នះ (ពីមុនហៅ ផ្លូវទំនប់កប់ស្រូវ) និងផ្លូវ ១៥១ រហូតដល់វត្តភ្នំរាប។ បឹងនេះគ្របដណ្តប់លើខណ្ឌចំនួន ២ សង្កាត់ចំនួន ៦ និងភូមិចំនួន ២៥។




ផែនទី ទី១៖ ទីតាំងភូមិសាស្ត្រនៃបឹងតាមោក ឬបឹងកប់ស្រូវ

# ៣. ប្រជាសាស្ត្រ

នៅជុំវិញបឹងតាមោក មានប្រជាជនប្រមាណ ៣០០គ្រួសារ និងមនុស្សប្រហែល ១០០០នាក់[១] កំពុងរស់នៅ។ គ្រួសារភាគច្រើនប្រកបរបរចិញ្ចឹមជីវិតដោយការនេសាទត្រី ដាំដំណាំ ចិញ្ចឹមត្រី និងរកស៊ីលក់ដូរបន្តិចបន្តួចនៅផ្ទះ[២]។ លំនៅឋានភាគច្រើនមានទំហំតូច មិនសូវរឹងមាំ ស្ថិតនៅកណ្តាលបឹង ឬជាប់មហាវិថីឈ្នះ-ឈ្នះ។

ការសិក្សាស្រាវជ្រាវរបស់អង្គការសមាគមធាងត្នោតចន្លោះពីខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០១៩ អំពីបឹងតាមោក បានរកឃើញថា ៧១គ្រួសារ កំពុងប្រឈមនឹងការបណ្តេញចេញ ១៥ទៅ ២៥គ្រួសារ ប្រឈមនឹងហានិភ័យខ្ពស់នៃការបណ្តេញចេញ ហើយយ៉ាងហោចណាស់ ២០៤គ្រួសារ ប្រឈមនឹងហានិភ័យនៃការបណ្តេញចេញនៅថ្ងៃមុខ។ ផលប៉ះពាល់ធ្ងន់ធ្ងរមួយចំនួននៃការបណ្តេញចេញមានដូចជាការបាត់បង់លំនៅឋាន និងប្រាក់ចំណូល ការខាតបង់ការសិក្សារបស់ក្មេង អំពើហិង្សា និងបំណុល[៣]។ គ្រួសារជាច្រើនបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬអ្នកផ្តល់ប្រាក់កម្ចីក្រៅផ្លូវការ ដើម្បីទិញឧបករណ៍នេសាទ និងចិញ្ចឹមត្រី ដែលជាហេតុធ្វើឱ្យបំណុលរបស់ពួកគេកើនឡើងកាន់តែច្រើន នៅពេលដែលពួកគេមានភាពលំបាកក្នុងការរកប្រាក់សង។ បើសិនឧបករណ៍ទាំងនោះត្រូវបានបំផ្លាញចោលដោយអាជ្ញាធរអំឡុងពេលធ្វើការបណ្តេញចេញ នោះបំណុលពួកគេនឹងកើន ហើយគ្រួសារជាច្រើននឹងត្រូវរងទុក្ខលំបាក។

ក្រៅពីផ្តល់អត្ថប្រយោជន៍ដល់គ្រួសារដែលរស់នៅជុំវិញបឹង បឹងនេះក៏ផ្តល់ជាប្រព័ន្ធអេកូដ៏សម្បូរបែបនៃសត្វត្រី និងសត្វស្លាបផងដែរ។



រូបភាព ទី១៖ អ្នកនេសាទត្រីក្នុងបឹងតាមោក ឆ្នាំ២០១៩

[១] ការសិក្សារបស់អង្គការសមាគមធាងត្នោតអំឡុងខែកុម្ភៈ ឆ្នាំ២០១៩
[២] ដូចខាងលើ
[៣] របាយការណ៍សង្ខេបរបស់អង្គការសមាគមធាងត្នោតអំពីការបណ្តេញចេញនៅបឹងតាមោក

# ៤. សាវតារបឹងតាមោក

## ៤.១. ពីចន្លោះឆ្នាំ ១៩៧០ ដល់ ២០១៦

យោងតាមប្រជាពលរដ្ឋដែលបានរស់នៅបឹងតាមោកចាប់តាំងពីដើមទស្សវត្សឆ្នាំ១៩៨០ ផ្នែកមួយចំនួននៃបឹងត្រូវបានប្រើប្រាស់ជាដីកសិកម្មនៅរដូវប្រាំងសម្រាប់កសិករដាំត្រកួន និងឈូក។ នៅរដូវវស្សា ទឹកហូរចូលតំបន់ទំនាបលិចទឹកនៃបឹងនេះ ផ្តល់ជាអាងស្តុកទឹកធម្មជាតិសម្រាប់រាជធានីភ្នំពេញ។ កាលពីមុនទីតាំងនេះជាវាលស្រែប្រាំង និងមានព្រែកមួយដែលប្រជាពលរដ្ឋប្រើសម្រាប់បូមទឹកដើម្បីធ្វើស្រែ។ ព្រែកនោះមានឈ្មោះថា ព្រែកព្នៅ ដែលហូរពីស្ពានព្រែកព្នៅ ដល់ភូមិធំ នៃសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅបច្ចុប្បន្ន។ ប៉ុន្តែ បន្ទាប់ពីស្ពានព្រែកព្នៅ និងទំនប់កប់ស្រូវត្រូវបានសាងសង់រួច លំហូរទឹកចូលបឹងត្រូវបានបញ្ឈប់ ហើយទឹកកខ្វក់ពីរាជធានីភ្នំពេញត្រូវបានគេចាប់ផ្តើមបង្ហូរចូលក្នុងបឹងនេះ ដែលនាំឱ្យបាត់បង់ស្រែប្រាំងសម្រាប់ប្រជាពលរដ្ឋធ្វើកសិកម្ម។ លើសពីនេះ ផ្នែកមួយចំនួននៃបឹងត្រូវបានជីកកាយយកដី ធ្វើឱ្យផ្នែកនៃបឹងនេះមានកាន់តែជ្រៅ។

យោងតាមរូបថតមួយសន្លឹកបានមកពីហ្គូហ្គល (Google) នៅឆ្នាំ២០១២ បឹងហាក់ដូចជាមានការប្រែប្រួលជាច្រើន (ផែនទី ទី ២)។




ផែនទី ទី២៖ រូបភាពពីផ្កាយរណបហ្គូហ្គល (Google) ខែឧសភា ឆ្នាំ២០១២ និងខែមេសា ឆ្នាំ២០២០

## ៤.២. ព្រំប្រទល់បឹងកំណត់ក្នុងឆ្នាំ ២០១៦

នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ២០ សម្រេចកំណត់ផ្ទៃបឹងតាមោក ឬបឹងកប់ស្រូវជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលមាន ៦១ចំណុច (ពី P1 ដល់ P61) និងទំហំផ្ទៃសរុប ៣២៣៩,៧ ហិកតា[៤]។

ស្របពេលជាមួយគ្នា អង្គការសមាគមធាងត្នោតបានធ្វើបទសម្ភាសជាមួយប្រធានភូមិចំនួន ១៩នាក់ និងប្រជាពលរដ្ឋដែលរស់នៅជុំវិញបឹង។ គ្រួសារចំនួន ៣៣២ ខ្នងផ្ទះអាចនឹងទទួលរងផលប៉ះពាល់ពីអនុក្រឹត្យនេះ ក្នុងនោះមាន ចំនួន១៤៧ គ្រួសារទទួលផលប៉ះពាល់ដល់ដីកសិកម្មរបស់ពួកគេ។ ប្រជាពលរដ្ឋព្រួយបារម្ភថា ថ្វីបើបឹងនេះត្រូវបានប្រកាសជាសម្បត្តិសាធារណៈរបស់រដ្ឋក្តី រាជរដ្ឋាភិបាលអាចយកដីបឹងនេះសម្រាប់គោលបំណងអភិវឌ្ឍន៍ដែលបង្កឱ្យមានការបណ្តេញចេញ និងផលប៉ះពាល់ជាអវិជ្ជមានផ្សេងទៀត[៥]។

ទោះបីជាមានការកំណត់ផ្ទៃ និងព្រំប្រទល់បឹង ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋក៏ដោយ ការកែសម្រួលផ្ទៃបឹងនៅតែបានធ្វើឡើងជាច្រើនដង។ យោងតាមប្រជាពលរដ្ឋរស់នៅជុំវិញបឹង បានអះអាងថា ពួកគាត់មិនទទួលចំណែកណាមួយនៃដីនោះឡើយ តែផ្ទុយមកវិញដីបឹងត្រូវបានផ្តល់ឱ្យមេឈ្មួញ និងក្រុមអ្នកមានទៅវិញ។




ផែនទី ទី៣៖ ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២០ ឆ្នាំ២០១៦

[៤] https://drive.google.com/file/d/1_I_P9UO1bJmnG8vwNEUIygbPs2IV2s_K/view?usp=sharing

[៥] របាយការណ៍របស់អង្គការសមាគមធាងត្នោតឆ្នាំ ២០១៦ ស្តីពីផលប៉ះពាល់នៃអនុក្រឹត្យស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ជាសម្បត្តិសាធារណៈរបស់រដ្ឋ អាចទាញយកបានតាម https://teangtnaut.org/impact-sub-decree-classify-tumnop-kopsrov-state-public-property/

## ៤.៣. ការសាងសង់ផ្លូវកាត់បឹង

ក្នុងចន្លោះខែមិថុនា ដល់ខែកក្កដា ឆ្នាំ២០១៦ ផ្លូវមួយខ្សែត្រូវបានសាងសង់ពីស្ថានីយ៍បូមទឹកទួលសំពៅ នៅប៉ែកខាងត្បូងនៃបឹង រហូតដល់ផ្លូវ ១៥១ នៅប៉ែកខាងជើង។ ផ្លូវនេះមានប្រវែងប្រមាណ ៤ គីឡូម៉ែត្រ និងទំហំ ៦០ ម៉ែត្រ[៦]។ ការអភិវឌ្ឍនេះគឺជាចំណុចចាប់ផ្តើមនៃការប្រែប្រួលដែលកើតមាន ហើយនឹងធ្វើឱ្យទិដ្ឋភាពបឹងនេះមានការផ្លាស់ប្តូរនៅពេលខាងមុខ។




ផែនទី ទី៤៖ ផ្លូវដែលកាត់ចំកណ្តាលបឹងតាមោក

៦ រូបភាពពីផ្កាយរណបហ្គូហ្គល (Google)

# ៥. ពេលវេលានៃការកែសម្រួលផ្ទៃបឹងតាមោក

## ៥.១. ផ្ទៃបឹងកែសម្រួលក្នុងខែតុលា ឆ្នាំ២០១៨

យោងតាមអនុក្រឹត្យលេខ ១៣២ ចេញថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ផ្ទៃដី ៤៥៦ ៥៥៣ ម៉ែត្រការ៉េ (៤៥,៦៥ ហិកតា) នៃផ្ទៃបឹងសរុប ៣២៣៩,៧ ហិកតា ត្រូវបានប្រកាសជាសម្បត្តិឯកជនរបស់រដ្ឋ។ ដីនេះលាតសន្ធឹងលើភូមិចំនួន ៤ រួមមានភូមិព្រៃស្វាយ ភូមិត្នោតខ្ពស់ ភូមិទួល និងភូមិបឹងខ្ទុំ ស្ថិតក្នុងសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ ត្រូវបានកាត់ឱ្យទៅលោក ស៊ី ជីនម៉ូវ[៧]។




ផែនទី ទី៥៖ ទីតាំងដីកាត់ឱ្យលោក ស៊ី ជីនម៉ូវ ក្នុងឆ្នាំ២០១៨

[៧] https://drive.google.com/file/d/13jWhYWaj18RTyR9PjOSrci6d9aB0x7_-/view?usp=sharing

## ៥.២. ផ្ទៃបឹងកែសម្រួលក្នុងខែវិច្ឆិកា ឆ្នាំ២០១៨

យោងតាមអនុក្រឹត្យលេខ ១៤៧ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៨ ផ្ទៃដី ២០ ហិកតាត្រូវបានសម្រេចជាសម្បត្តិឯកជនរបស់រដ្ឋ។ ដីនេះត្រូវបានផ្តល់ឱ្យសាលារាជធានីភ្នំពេញ ដើម្បីអភិវឌ្ឍន៍ ធ្វើផ្សារផ្គត់ផ្គង់បន្លែ និងចំណតរថយន្ត។ មានបីគ្រួសារ ដែលពួកគាត់រស់នៅលើដី ២០ ហិកតានេះ បានរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍នេះ។ ជាលទ្ធផល គ្រួសារទាំងបីនេះ ត្រូវបានបណ្តេញចេញ និងត្រូវបង្ខំផ្លាស់ទីលំនៅទៅប៉ែកខាងកើតនៃបឹងដោយគ្មានសំណង[៩]។




ផែនទី ទី៦៖ ទីតាំងដីកាត់ឱ្យសាលារាជធានីភ្នំពេញ ក្នុងឆ្នាំ២០១៨

[៩] https://drive.google.com/file/d/1ywdiIAZtSqnEIAqBciIA39C--_m_1Dpo/view?usp=sharing

## ៥.៣. ផ្ទៃបឹងកែសម្រួលក្នុងខែមេសា ឆ្នាំ២០១៩

ផ្ទៃបឹងនេះត្រូវបានកែសម្រួលសារជាថ្មីក្នុងខែមេសា ឆ្នាំ២០១៩។ យោងតាមអនុក្រឹត្យលេខ ៦២ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ផ្ទៃដី ៥៣៥ ០៣១ ម៉ែត្រការ៉េត្រូវបានសម្រេចជាសម្បត្តិឯកជនរបស់រដ្ឋ និងផ្តល់ទៅឱ្យបុគ្គលពីររូប។ ក្នុងនោះដីទំហំ ៤៥៧ ៨៩៣ ម៉ែត្រការ៉េ នៃផ្ទៃដីនេះត្រូវបានផ្តល់ឱ្យឈ្មោះ ស៊ុយ សុផាន និងដីទំហំ ៧៧ ១៣៨ ម៉ែត្រការ៉េបានផ្តល់ឱ្យឈ្មោះ ម៉ែន សុខ[៩]។




ផែនទី ទី៧៖ ដី ៤៥,៧៩ ហិកតាផ្តល់ឱ្យឈ្មោះ ស៊ុយ សុផាន និង ដី ៧,៧១ ហិកតាផ្តល់ឱ្យឈ្មោះ ម៉ែន សុខ

[៩] https://drive.google.com/file/d/19vCiuxNuZ8iFdUofXdnidO-MOIoOfb8k/view?usp=sharing

## ៥.៤. ផ្ទៃបឹងកែសម្រួលក្នុងខែមីនា ឆ្នាំ២០២០

យោងតាមសេចក្តីជូនដំណឹង (សជណ) លេខ ៣៦៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចេញថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០[១០] ដី ៧៥ ហិកតា ត្រូវបានកាត់ឱ្យសាលារាជធានីភ្នំពេញ ដើម្បីបង្កើតសួនឧទ្យាន។ នៅថ្ងៃដដែលមានសេចក្តីជូនដំណឹង លេខ ៣៦៩ មួយទៀត បានផ្តល់ដី ៨ ហិកតាទៅឱ្យនាយកដ្ឋានកណ្តាលសន្តិសុខនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ[១១]។




ផែនទី ទី៨៖ ដី ៧៥ ហិកតាផ្តល់ឱ្យសាលារាជធានីភ្នំពេញ និងដី ៨ហិកតាផ្តល់ឱ្យនាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ

---

[១០] https://drive.google.com/file/d/1OmYQD0SX5LIzoQS6sWid1LeJPJoAzoKy/view?usp=sharing
[១១] https://drive.google.com/file/d/1uWC72qzRjRrM4cI2cnpFZy0RRFNdlHkK/view?usp=sharing

## ៥.៥. ផ្ទៃបឹងកែសម្រួលក្នុងខែមិថុនា ឆ្នាំ២០២០

ផ្ទៃបឹងនេះត្រូវបានកែសម្រួលម្ដងទៀតនៅក្នុងខែមិថុនា ឆ្នាំ២០២០។ យោងតាមអនុក្រឹត្យលេខ ៨៩ ដី ១០៤ ៧៥៤ ម៉ែត្រការ៉េ (១០,៤៨ ហិកតា) ត្រូវបានកាត់ឱ្យលោកស្រី ជា សុផាម៉ាដែន ដែលត្រូវជាកូនស្រីរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់[១២]។




ផែនទី ទី៩៖ ដី ១០៤ ៧៥៤ ម៉ែត្រការ៉េកាត់ឱ្យឈ្មោះ ជា សុផាម៉ាដែន

[១២] https://drive.google.com/file/d/1EotuYwgfttP9agvTxOeOYzJnp2NRwjWu/view?usp=sharing

## ៥.៦. ផ្ទៃបឹងកែសម្រួលក្នុងខែមិថុនា ឆ្នាំ២០២០

នៅក្នុងខែដដែល តាមរយៈអនុក្រឹត្យលេខ ៩០ រដ្ឋាភិបាលបានសម្រេចផ្តល់ដី ២ ៩៨៥ ៤៧២ ម៉ែត្រការ៉េ (២៩៨,៥៥ ហិកតា) ប្រគល់ឱ្យក្រសួងការពារជាតិ[១៣]។




ផែនទី ទី១០៖ ដី ២៩៨,៥៥ ហិកតាកាត់ឱ្យក្រសួងការពារជាតិ

១៣ https://drive.google.com/file/d/1ZqcI2eq7RyaQz3zFJTDLIJJWqmzOtpL-/view?usp=sharing

## ៥.៧. ផ្ទៃបឹងកែសម្រួលក្នុងខែកក្កដា ឆ្នាំ២០២០

យោងតាមអនុក្រឹត្យលេខ ៩៤ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០ ផ្ទៃបឹងទំហំ ៣០ ហិកតាត្រូវបានផ្តល់ឱ្យលោកស្រី គឹម ហ៊ាង ដែលត្រូវជាភរិយារបស់លោក លី យ៉ុងផាត់[១៤]។




ផែនទី ទី១១៖ ដី ៣០ ហិកតាកាត់ឱ្យលោកស្រី គឹម ហ៊ាង

[១៤] https://drive.google.com/file/d/1uWC72qzRjRrM4cI2cnpFZy0RRFNdIHkK/view?usp=sharing

## ៥.៨. ផ្ទៃបឹងកែសម្រួលក្នុងខែសីហា ឆ្នាំ២០២០

យោងតាមអនុក្រឹត្យលេខ១២៥ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២០ ផ្ទៃបឹងចំនួន ៧,៤៨៥ ហិកតា[១៥] ត្រូវបានផ្តល់ឱ្យ ២៣ គ្រួសារ។ អនុក្រឹត្យនេះបានបញ្ជាក់ថាគ្រួសារទាំងនេះគឺជាម្ចាស់ដើម ដែលបានកាន់កាប់ដីនេះ មុនពេលបឹងតាមោកត្រូវបានប្រកាសជាសម្បត្តិសាធារណៈរបស់រដ្ឋក្នុងឆ្នាំ២០១៦។ បច្ចុប្បន្នដីមួយដុំនេះនៅទំនេរ ហើយជន់លិចផ្នែកខ្លះ និងមានរបងថ្មតដ្ឋកំពុងត្រូវបានគេសង់ព័ទ្ធជុំវិញទីតាំងនេះ។




ផែនទី ទី១២៖ ដី ៧៤ ៨៥៥ ម៉ែត្រការ៉េ កាត់ឱ្យ ២៣គ្រួសារ

[១៥] https://drive.google.com/file/d/1I0mDnkMHGWnSIthy4Kf8m8USU6NRQwfv/view?usp=sharing

## ៥.៩. ផ្ទៃបឹងកែសម្រួលក្នុងខែកញ្ញា ឆ្នាំ២០២០

យោងតាមអនុក្រឹត្យលេខ ១៣៨ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ដីទំហំ ១៥០ ៣៣០ ម៉ែត្រការ៉េ នៃផ្ទៃបឹងតាមោក ត្រូវបានផ្តល់ឱ្យក្រសួងអភិវឌ្ឍន៍ជនបទ ហើយដី ៨០ ២៣៦ ម៉ែត្រការ៉េទៀតត្រូវបានកាត់ឱ្យឈ្មោះ សេង វុទ្ធី[១៦]។




ផែនទី ទី១៣៖ ដី ១៥,០៣៣ ហិកតា កាត់ឱ្យក្រសួងអភិវឌ្ឍន៍ជនបទ និង ដី ៨,០២ ហិកតាកាត់ឱ្យឈ្មោះ សេង វុទ្ធី

*កំណត់សម្គាល់៖ នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដកហូតយកដី ១៥ ហិកតា ដែលបានកាត់ឱ្យក្រសួងអភិវឌ្ឍន៍ជនបទ យោងតាមសេចក្តីជូនដំណឹង លេខ ៤[១៧]។

[១៦] https://drive.google.com/file/d/1aS3vWJF5QQYtf8QQ45F2EtP1bpOReiDL/view?usp=sharing

[១៧] https://drive.google.com/file/d/1l0k3ZRqkKmbDA_HZ7bIIfqYxzxjsmkzj/view?usp=sharing

### ៥.១០. ផ្ទៃបឹងកែសម្រួលក្នុងខែកញ្ញា ឆ្នាំ២០២០

យោងតាមអនុក្រឹត្យលេខ ១៣៩ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ផ្ទៃដី ១៥០ ០០០ ម៉ែត្រការ៉េ នៃផ្ទៃបឹងត្រូវបានកាត់ឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក) និងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន(អាជ្ញាធរមីន)[១៨]។




ផែនទី ទី១៤៖ ដី១៥ ហិកតាកាត់ឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

*កំណត់សម្គាល់៖ នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានដកហូតយកដី ១៥០ ០០០ ម៉ែត្រការ៉េដែលបានកាត់ឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការសិទ្ធិ មនុស្សកម្ពុជា និងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន យោងតាមលិខិត សជណ លេខ ៤[១៩]។

[១៨] https://drive.google.com/file/d/101vr1tQRdNwH78HPIeBo06D7MZlRl1aw/view?usp=sharing

[១៩] https://drive.google.com/file/d/1l0k3ZRqkKmbDA_HZ7bIIfqYxzxjsmkzj/view?usp=sharing

## ៥.១១. ផ្ទៃបឹងកែសម្រួលក្នុងខែកញ្ញា ឆ្នាំ២០២០

បន្ថែមពីនេះ ក្នុងខែកញ្ញា ឆ្នាំ២០២០ ដីទំហំ ៨ ហិកតាទៀតត្រូវបានផ្តល់ឱ្យក្រសួងយុត្តិធម៌ ដែលបានអះអាងថាមន្ត្រីរបស់ខ្លួនត្រូវការកន្លែងបន្ថែម ដើម្បីធ្វើជាការិយាល័យ និងឃ្លាំងរក្សាទុកឯកសារ[២០]។




ផែនទី ទី១៥៖ ដី ៨ ហិកតាកាត់ឱ្យក្រសួងយុត្តិធម៌

[២០] https://drive.google.com/file/d/14mfxu7atXjJKFd03sQDyCZxsSEe9x1kk/view?usp=sharing

## ៥.១២. ផ្ទៃបឹងកែសម្រួលក្នុងខែតុលា ឆ្នាំ២០២០

យោងតាមអនុក្រឹត្យលេខ ១៧៥ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ ដីទំហំ ៧៨ ៣១៤ ម៉ែត្រការ៉េនៃដីបឹងត្រូវបានកាត់ឱ្យឈ្មោះ សាយ សោភា[២១]។




ផែនទី ទី១៦៖ ដី ៧៨ ៣១៤ ម៉ែត្រការ៉េកាត់ឱ្យឈ្មោះ សាយ សោភា

[២១] https://drive.google.com/file/d/1Yk0ghYIO0no30iAv9ZMI7wqCh1re6UcO/view?usp=sharing

## ៥.១៣. ផ្ទៃបឹងកែសម្រួលក្នុងខែធ្នូ ឆ្នាំ២០២០

យោងតាមសេចក្តីជូនដំណឹង លេខ ១០៩៩ ចុះហត្ថលេខានៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ដីទំហំ ២០ ហិកតានៃបឹងតាមោកត្រូវបានផ្តល់ឱ្យទៅឈ្មោះ លន់ ហាក់ និងឈ្មោះ ឈុន ចាន់ធី ជាថ្នូរជាមួយដីទំហំ ១៥៧១,២ ម៉ែត្រការ៉េនៅក្នុងសង្កាត់ស្រះចកខណ្ឌដូនពេញ[២២]។




ផែនទី ទី១៧៖ ដី ២០ ហិកតាកាត់ឱ្យឈ្មោះ លន់ ហាក់ និងឈ្មោះ ឈុន ចាន់ធី

*កំណត់សម្គាល់៖ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានដកហូតយកដីនេះវិញ យោងតាមអនុក្រឹត្យលេខ ៨[២៣]។

[២២] https://drive.google.com/file/d/1s85-x1iKE2XTEr1OalMrgmIiIV2OJ7o8/view?usp=sharing
[២៣] https://drive.google.com/file/d/1WH7sMqs9-4Xk5zxHIDRWCn8-0Stg1GF4/view?usp=sharing

## ៥.១៤. ផ្ទៃបឹងកែសម្រួលក្នុងខែធ្នូ ឆ្នាំ២០២០

យោងតាមសេចក្តីជូនដំណឹង លេខ ១១០០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ដីទំហំ ២០ ហិកតានៃដីបឹងត្រូវបានកាត់ និងប្រគល់ឱ្យក្រសួងសុខាភិបាលដើម្បីសាងសង់មន្ទីរពេទ្យកាល់ម៉ែត្រ[២៤]។




ផែនទី ទី១៨៖ ដី ២០ ហិកតាកាត់ឱ្យក្រសួងសុខាភិបាល

---

[២៤] https://drive.google.com/file/d/1aS3vWJF5QQYtf8QQ45F2EtP1bpOReiDL/view?usp=sharing

## ៥.១៥. ផ្ទៃបឹងកែសម្រួលក្នុងខែធ្នូ ឆ្នាំ២០២០

យោងតាមសេចក្ដីជូនដំណឹង លេខ ១១០២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ដីទំហំ ១៩៦,៥៦៥៩ ហិកតា នៃដីបឹងត្រូវបានសម្រេចកាត់ឱ្យអ្នកស្រី អ៊ុយ បូរី និងអ្នកស្រី គង់ សុធី[២៥]។




ផែនទី ទី១៩៖ ដី ១៩៦,៥៦៥៩ ហិកតាកាត់ឱ្យអ្នកស្រី អ៊ុយ បូរី និងអ្នកស្រី គង់ សុធី

---

[២៥] https://drive.google.com/file/d/1ArHyhNuCdZEfDsqKIpD_HVWgre6fg0Jo/view?usp=sharing

## ៥.១៦. ផ្ទៃបឹងកែសម្រួលក្នុងខែធ្នូ ឆ្នាំ២០២០

យោងតាមសេចក្តីជូនដំណឹង លេខ ១១០៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ដីទំហំ ២៧ ៦៥៩ ម៉ែត្រការ៉េ នៃដីបឹងត្រូវបានសម្រេចកាត់ និងប្រគល់ឱ្យកងរាជអាវុធហត្ថ ១៦ គ្រួសារ[២៦]។




ផែនទី ទី២០៖ ដី ២៧ ៦៥៩ ម៉ែត្រការ៉េកាត់ឱ្យកងរាជអាវុធហត្ថ ១៦ គ្រួសារ

[២៦] https://drive.google.com/file/d/17sGWbcPOMwtzGbeJxnGvpzE5bYX4KjMR/view?usp=sharing

## ៥.១៧. ផ្ទៃបឹងកែសម្រួលក្នុងខែមករា ឆ្នាំ២០២១

យោងតាមសេចក្តីជូនដំណឹង លេខ ៦៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ដីទំហំ ៤ ហិកតាត្រូវបានសម្រេចកាត់ និងផ្តល់ឱ្យក្រសួងមុខងារសាធារណៈ[២៧]។




ផែនទី ទី២១៖ ដី ៤ ហិកតាកាត់ឱ្យក្រសួងមុខងារសាធារណៈ

[២៧] https://drive.google.com/file/d/1rAAe4bf0eoyPWq-I7TT3tBYOsLBw4Uam/view?usp=sharing

# ៦. កំហុសបច្ចេកទេស

ក្នុងការកែសម្រួលផ្ទៃបឹងលើកទីពីរ   រាជរដ្ឋាភិបាលបានដាក់ចេញនូវប្រព័ន្ធនិយាមការថ្មីសម្រាប់កំណត់ព្រំប្រទល់បឹងតាមោក និងបានបង្កើតកំហុសបច្ចេកទេសសំខាន់ចំនួនពីរ។ ទីមួយគឺរាជរដ្ឋាភិបាលមិនបានកាត់ដីឱ្យលោក ស៊ី ជិនម៉ូវ ដូចបានកំណត់ក្នុងឆ្នាំ ២០១៨។ ទីពីរ គឺប្រព័ន្ធនិយាមការថ្មីប្រើដើម្បីកំណត់ព្រំប្រទល់បឹងបានបង្កឱ្យមានភាពខុសគ្នារវាងព្រំប្រទល់បឹងថ្មី និងព្រំប្រទល់បឹងចាស់ ជាហេតុបណ្តាលឱ្យបាត់ដីបឹងចំនួន ២២,៧ ហិកតា (ដូចមានបង្ហាញនៅលើផែនទី ទី២២៖ ផែនទីបង្ហាញទីតាំងកំហុស)។

# ៧. ការពិភាក្សា




ផែនទី ទី២២៖ ផែនទីបង្ហាញទីតាំងកំហុសបច្ចេកទេសពេលប្រើនិយាមការថ្មី

ការកំណត់ផ្ទៃបឹងជាសម្បត្តិសាធារណៈរបស់រដ្ឋបានបង្កនូវផលប៉ះពាល់យ៉ាងខ្លាំងដល់សហគមន៍ ដែលរស់នៅជុំវិញបឹងនេះ។ ទោះបីជាផ្ទៃបឹងនេះត្រូវបានកំណត់ក្នុងឆ្នាំ២០១៦ ក្តី ភាគីពាក់ព័ន្ធទាំងអស់មិនទទួលបានការពិគ្រោះយោបល់ និង លទ្ធភាពចូលរួមក្នុងដំណើរការកំណត់ផ្ទៃបឹងនោះទេ។ ដំណើរការកំណត់មិនមានតម្លាភាព និងមិនបានគិតគូរអំពីសិទ្ធិប្រជាពលរដ្ឋដែលប្រើប្រាស់បឹងនេះប្រចាំថ្ងៃ។ នៅមានចំណុចមិនច្បាស់លាស់មួយចំនួន ទាក់ទងនឹងព្រំប្រទល់បឹងជាក់លាក់ ជាពិសេសព្រំប្រទល់នៅខាងផ្លូវកប់ស្រូវ ដែលធ្វើឱ្យសហគមន៍ក្រីក្រនៅទីក្រុងមានភាពស្រពេចស្រពិលអំពីសិទ្ធិរបស់ពួកគេក្នុងការរស់នៅលើដីនោះ ឬសាងសង់លំនៅឋានថ្មី[២៨]។ លើសពីនេះ តំបន់ដែលត្រូវបានដាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ បច្ចុប្បន្នមានភូមិជាច្រើន និងមានគ្រួសារដែលបានតាំងទីលំនៅអស់រយៈពេលជាច្រើនទសវត្សមកហើយ។ ហេតុនេះបានបង្កឱ្យមានជម្លោះដីធ្លីជាច្រើនរវាងសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។

នៅក្នុងឆ្នាំ២០១៩ អាជ្ញាធរខណ្ឌព្រែកព្នៅបានបញ្ជាឱ្យគ្រួសារ ជាច្រើនរើចេញពីបឹងតាមោក ក្នុងរយៈពេលប្រាំពីរថ្ងៃ ដោយ ចោទប្រកាន់ប្រជាពលរដ្ឋថារស់នៅលើដីបឹង និងសាងសង់លំនៅឋាន ដោយគ្មានការអនុញ្ញាត។ ការចោទប្រកាន់នេះត្រូវបានគេចោទសួរអំពីចន្លោះដី ៣០ ម៉ែត្ររវាងព្រំប្រទល់បឹង និងផ្លូវកប់ស្រូវ។ សហគមន៍មូលដ្ឋានទាំងនោះរស់នៅលើចន្លោះដីនេះ ដូច្នេះព្រំប្រទល់បឹងមិនមានភាពច្បាស់លាស់ ធ្វើឱ្យប្រជាពលរដ្ឋមិនដឹងថាពួកគេអាចរស់នៅកន្លែងណាបាន។ បើសិនជាព្រំប្រទល់មានលក្ខណៈស្រពេចស្រពិល និងមិនមានភាពច្បាស់លាស់ សហគមន៍នឹងមានការលំបាកក្នុងការចរចារជាមួយអាជ្ញាធរ ហើយការបណ្តេញចេញដោយមិនមានភាពត្រឹមត្រូវនឹងអាចកើតមាន។

[២៨] https://drive.google.com/file/d/13eylcqKc_Wc8WU2Kb8q1VH4HOC6jV0Ow/view?usp=sharing



ផែនទី ទី២៣៖ ទីតាំងស្តុកទឹកកខ្វក់ក្នុងបឹង



រូបភាព ទី៣៖ ដីចាក់បំពេញបឹង ថតក្នុងឆ្នាំ២០១៩



ផែនទី ទី២៤៖ ទីតាំងដីកាន់កាប់ដោយឯកជនធ្វើជាចំការ



រូបភាព ទី៤៖ ទីតាំងចំការឪឡឹកលើដីបឹងក្នុងឆ្នាំ២០១៩



ផែនទី ទី២៥៖ ទីតាំងបង្គោលដាំក្នុងបឹង



រូបភាព ទី៥៖ បង្គោលក្នុងបឹង



ផែនទី ទី២៦៖ ទីតាំងរុក្ខជាតិដែលមានអាយុកាលជាង២០ឆ្នាំ



រូបភាព ទី៦៖ ដើមត្នោត និងវាលស្រែលើដីបឹងកំណត់ដោយអនុក្រឹត្យឆ្នាំ ២០១៦ (ថតក្នុងឆ្នាំ២០១៩)

គ្រួសារជាច្រើនត្រូវបានផ្តល់ដំណឹងអំពីការបណ្តេញចេញក្នុងឆ្នាំ២០២០ ទោះបីជាជំងឺរាតត្បាតកូវីដ-១៩កំពុងតែកើតមានក្តី[២៩]។ អ្នកនេសាទត្រូវបានប្រាប់ឱ្យរើឧបករណ៍នេសាទរបស់ខ្លួនចេញពីបឹងឱ្យបានមុនដាច់ឆ្នាំ[៣០]។ ពួកគេត្រូវបានបង្ខំឱ្យចុះកិច្ចសន្យាទទួលយកលក្ខខណ្ឌ ហើយពួកគេនឹងបាត់បង់ចំណូលនិងជីវភាពរបស់ខ្លួនដោយមិនទទួលបានសំណង។ ការតាំងទីលំនៅថ្មីក៏នឹងបង្កផលប៉ះពាល់ជាអវិជ្ជមានដល់កុមារផងដែរ ព្រោះកុមារទាំងនោះនឹងត្រូវខកខានទទួលបានការអប់រំ ហើយអាចប្រឈមនឹងការគ្មានលំនៅឋានសមរម្យសម្រាប់រស់នៅ[៣១]។

ផ្អែកតាមទស្សនាទានបរិស្ថាន បឹងតាមោកដើរតួជាអាងស្តុកទឹកភ្លៀងសម្រាប់រាជធានីភ្នំពេញ ដែលជួយកាត់បន្ថយទឹកជំនន់ក្នុងទីក្រុង និងតំបន់ជុំវិញបឹងបានយ៉ាងមានប្រសិទ្ធភាព។ បឹងនេះត្រូវបានចាក់បំពេញដើម្បីអភិវឌ្ឍន៍ ដោយមិនមានការធ្វើការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថានបានត្រឹមត្រូវធ្វើឱ្យប្រជាពលរដ្ឋរាប់លាននាក់អាចរងផលប៉ះពាល់ដោយសារទឹកជំនន់[៣២]។

យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ទ្រព្យសម្បត្តិសាធារណៈ របស់រដ្ឋមិនអាចលក់ដូរបានឡើយ តែអាចធ្វើអនុបយោគជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋបាន នៅពេលដែលទ្រព្យនោះលែងផ្តល់ប្រយោជន៍សាធារណៈ[៣៣]។ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋអាចលក់ដូរ ជួល និងបែងចែកតាមរយៈអនុក្រឹត្យ[៣៤]។

ព្រះរាជក្រឹត្យលេខ ៣៣៩ បានកំណត់នូវបទបញ្ញត្តិ និងនីតិវិធីស្តីពីការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ ដើម្បីធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ទ្រព្យនោះលែងជាតម្រូវការនៃផលប្រយោជន៍សាធារណៈ ឬ
- ទ្រព្យនោះ បាត់បង់លក្ខណៈសម្បត្តិពេញលេញរបស់ខ្លួនក្នុងការបម្រើប្រយោជន៍សាធារណៈ ឬ
- ទ្រព្យនោះលែងជាការប្រើប្រាស់ដោយផ្ទាល់ ដោយសាធារណជន[៣៥]។

ផ្អែកតាមលក្ខខណ្ឌទាំងនេះ គេពិបាកនឹងស្រមៃគិតថាបឹងនេះ បានបាត់បង់តួនាទីក្នុងការបម្រើប្រយោជន៍សាធារណៈនោះណាស់។ បឹងនេះនៅតែបម្រើប្រយោជន៍ដល់សាធារណជន តាមរយៈការកាត់បន្ថយគ្រោះទឹកជំនន់ និងជាប្រភពចំណូលសម្រាប់គ្រួសារជាច្រើន។ មួយភាគធំនៃផ្ទៃបឹងត្រូវបានបន្តផ្តល់ឱ្យបុគ្គលនិងក្រុមហ៊ុនឯកជន ទោះបីជាប្រជាពលរដ្ឋជាច្រើនកំពុងតែប្រើប្រាស់បឹងនេះក្តី[៣៦]។ ចំណុចសំខាន់ដែលគួរតែពិចារណាគឺថាតើការចាក់ដីលុបបឹងនេះបង្កអន្តរាយជាជាងផលប្រយោជន៍ ឬយ៉ាងណា ព្រោះវាបានធ្វើឱ្យប៉ះពាល់ វិនាសអន្តរាយ រួមមានការបណ្តេញចេញ ការកើនឡើងនៃទឹកជំនន់ ការបាត់បង់មុខរបររបស់ប្រជាជន ជីវចម្រុះ ការបំពុលបរិស្ថាន និងការបំផ្លាញប្រព័ន្ធអេកូ[៣៧]។ ការពិគ្រោះយោបល់សាធារណៈមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការគ្រប់គ្រងធនធានសាធារណៈ។ ការស្រាវជ្រាវគួរធ្វើឡើងនិងចែករំលែកដល់សាធារណជន ដើម្បីបង្ហាញពីទំហំនៃផ្ទៃបឹង ដែលត្រូវរក្សាទុកសម្រាប់បន្តបម្រើប្រយោជន៍សាធារណៈ។ ការវាយតម្លៃទាំងនេះគួរធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយក្រុមពាក់ព័ន្ធទាំងឡាយ និងដាក់អាទិភាពលើប្រយោជន៍សាធារណៈជាចម្បង ព្រោះ បើតាមទ្រឹស្តីបឹងគឺជាធនធានធម្មជាតិប្រើប្រាស់និង កាន់កាប់ដោយសាធារណជន។ វិធីសាស្ត្រនៃការគ្រប់គ្រងបឹងប្រកបដោយតុល្យភាពរវាងការការពារសិទ្ធិមនុស្ស បរិស្ថាន និងជីវចម្រុះជាមួយនឹងការអភិវឌ្ឍទីក្រុង អាចអនុវត្តទៅរួចដរាបណាមានការគិតគូរគ្រប់គ្រាន់អំពីតម្រូវការទាំងនេះ តាមរយៈការសិក្សានិងការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ។ លើសពីនេះ ក្រុមហ៊ុនទាំងអស់ត្រូវធានាថាគម្រោងរបស់ខ្លួន គិតគូរពីសិទ្ធិមនុស្ស ទាំងមុន អំឡុង និងក្រោយពេលបញ្ចប់គម្រោង។ ក្រុមហ៊ុនត្រូវតែធានាតម្លាភាពនៅក្នុងការអនុវត្តគម្រោងរបស់ខ្លួន និងគោរពតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស។

---

[២៩] https://www.phnompenhpost.com/national/ngo-report-govt-wrong-evict-poor

[៣០] https://www.phnompenhpost.com/national/deadline-vacate-phnom-penhs-largest-lake-set

[៣១] https://www.phnompenhpost.com/national/more-boeung-tamok-lake-area-residents-relocated

[៣២] https://www.phnompenhpost.com/national/lake-set-development

[៣៣] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ១៦

[៣៤] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ១៦

[៣៥] ព្រះរាជក្រឹត្យលេខស្តីពីគោលការណ៍ និងបញ្ញត្តិ អន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈ និងរបស់នីតិបុគ្គលសាធារណៈ មាត្រា ១ លេខ ៣៣៩ ឆ្នាំ២០០៦

[៣៦] https://www.rfa.org/english/news/cambodia/lake-07302020152159.html

[៣៧] https://www.rfa.org/english/news/cambodia/lake-07302020152159.html

## ករណីសិក្សា ទី១ – ការភ័យខ្លាចបាត់បង់ដីធ្លី

“ពីដំបូង ពួកយើងមានអារម្មណ៍តក់ស្លុតនៅពេលទទួលបានដំណឹងពីអាជ្ញាធរថាពួកយើងរស់នៅលើដីសាធារណៈរបស់រដ្ឋ ដោយសារពួកយើងមិនដែលបានដឹងទាល់តែសោះពីមុនមក។ សហគមន៍សំរោងត្បូងមានផ្ទះចំនួន ៩៨ខ្នង ដែលមាន ១០៨គ្រួសារកំពុងរស់នៅ។ ពួកយើងខ្លះរស់នៅទីនេះតាំងពីឆ្នាំ ១៩៩០ ហើយខ្លះទៀតតាំងពីឆ្នាំ ១៩៨០។ ពួកយើងគិតថាដីនេះជាកម្មសិទ្ធិរបស់ពួកយើង ព្រោះយើងបានទិញដីនេះ តែយើងទិញតាំងពីមុនច្បាប់ភូមិបាលត្រូវបានបង្កើតឡើង ហើយកាលពីមុនដីរបស់យើងគឺជាវាលស្រែ។ នៅពេលពួកយើងទទួលបានដំណឹងនេះពីអាជ្ញាធរ សហគមន៍យើងព្យាយាមតស៊ូមតិតាមរយៈការដាក់ញត្តិទៅអាជ្ញាធរមូលដ្ឋានចំនួនប្រាំបួនលើកដើម្បីប្រាប់អំពីបញ្ហានេះ។ ប៉ុន្តែអាជ្ញាធរមិនឆ្លើយតប ទោះបីជាពួកយើងធ្វើការតស៊ូមតិដោយសន្តិវិធីយ៉ាងណាក៏ដោយ។”

“ដីគឺជាអាយុជីវិតរបស់ពួកយើង ហើយបញ្ហាធំសម្រាប់ពួកយើងគឺការបាត់បង់ផ្ទះសម្បែង។ ពួកយើងបានព្យាយាមសុំធ្វើប្លង់ដី ដើម្បីអាចបន្តរស់នៅលើដីរបស់យើង។ ពួកយើងមិនចង់បាត់បង់ដីធ្លីនិងផ្ទះសម្បែងទេ។ វាមានសារៈសំខាន់ជាងមុខរបររបស់ ពួកយើងទៅទៀត។ ពួកយើងអាចរកការងារថ្មីធ្វើបាន ដូចជារត់ម៉ូតូឌុប និងកង់បី ប៉ុន្តែយើងមិនអាចរស់នៅដោយគ្មានដីធ្លីរបស់យើងបានឡើយ។ ពួកយើងបានទិញដីពីអ្នកលក់ ដោយជឿទុកចិត្តថាពួកគេទាំងនោះត្រឹមត្រូវ ហើយយើងបានរស់នៅលើដីនេះតាំងពីឆ្នាំ ១៩៩១។ ប្រជាពលរដ្ឋភាគច្រើនក្នុងសហគមន៍ប្រកបរបរនេសាទត្រីដើម្បីចិញ្ចឹមជីវិត។ តាមរយៈការនេសាទត្រី ខ្ញុំអាចចិញ្ចឹមគ្រួសារដែលមានសមាជិកបួននាក់របស់ខ្ញុំបានដោយសមរម្យ។ ប៉ុន្តែឥឡូវនេះបឹងកំពុងតែត្រូវបានគេចាក់បំពេញដើម្បីអភិវឌ្ឍន៍ ធ្វើឱ្យពួកយើងមានភាពលំបាកកាន់តែខ្លាំងក្នុងការរកត្រីសម្រាប់ហូប និងលក់ដូរ។ ដូច្នេះពួកយើងមិនអាចទ្រទ្រង់ជីវភាពរបស់ពួកយើងបានឡើយ។ ពួកយើងបានព្យាយាមប្រាប់ទៅអាជ្ញាធរថាបញ្ហានេះកំពុងប៉ះពាល់ដល់ជីវិតរបស់ពួកយើង និងស្នើសុំឱ្យអាជ្ញាធរជួយរកដំណោះស្រាយ ប៉ុន្តែអាជ្ញាធរមិនបានឆ្លើយតបទាល់តែសោះ។”

“សហគមន៍របស់ពួកយើងជួបប្រទះនឹងទឹកជន់។ ជាពិសេស ក្រោយពេលដែលអាជ្ញាធរបានបិទច្រកទឹកហូរ ទឹកមិនអាចហូរទៅកន្លែងផ្សេងបាន។ ដូចនេះ ទឹកនៅតែក្នុងសហគមន៍ ហើយពួកយើងពិបាករស់នៅយ៉ាងខ្លាំងអំឡុងពេលរដូវទឹកជន់។ ពួកយើងរស់នៅក្នុងភាពភ័យខ្លាចគ្រប់ពេល និងព្រួយបារម្ភមិនដឹងថាព័ត៌មាននេះ(ទឹកជន់) នឹងប៉ះពាល់យ៉ាងណាខ្លះដល់ពួកយើងនៅថ្ងៃមុខ។ ពួកយើងមិនអាចទៅធ្វើការនៅឆ្ងាយពីផ្ទះបាន ព្រោះខ្លាចអាជ្ញាធររើបំផ្លាញផ្ទះសម្បែង និងជីវភាពរបស់ពួកយើង។”



រូបភាព ទី៧៖ ផ្ទះក្នុងសហគមន៍សំរោងត្បូង

## ករណីសិក្សា ទី២ – ឱនភាពនៃស្ថានភាពហិរញ្ញវត្ថុរបស់កសិកររស់នៅជុំវិញបឹងតាមោក

"ខ្ញុំជាកសិករមួយរូប ហើយគ្រួសារខ្ញុំ និងខ្ញុំរស់នៅលើព្រំប្រទល់បឹងតាមោក ដែលត្រូវបានចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ពួកយើងបានមករស់នៅទីនេះតាំងពីឆ្នាំ ២០០០ បន្ទាប់ពីបានទិញដីនេះ។ ពួកយើងប្រកបរបរចិញ្ចឹមត្រីក្នុងបឹង និងយកត្រីទៅលក់នៅផ្សារ។ យើងចាប់ត្រីដោយប្រើសំណាញ់ ឬសន្ទូច ៤ទៅ៥ដងក្នុងមួយអាទិត្យ ហើយអាចរកចំណូលពីត្រីនេះបានគួរសម។ យើងបានមករស់នៅលើដីនេះជាង ២០ ឆ្នាំមកហើយ ប៉ុន្តែក្នុងពេលថ្មីៗនេះបឹងនេះមានការកែប្រែជាច្រើន។ ព្រំប្រទល់បឹងកាន់តែរួមតូចជាងមុន ដោយសារការចាក់បំពេញបឹង ធ្វើឱ្យពួកយើងពិបាកក្នុងការរកត្រី។ អាជ្ញាធរមូលដ្ឋានប្រាប់ថាពួកយើងកំពុងរស់នៅលើដីសាធារណៈរបស់រដ្ឋ និងបានប្រើម៉ាស៊ីនកម្ទេចកន្លែងចិញ្ចឹមត្រីរបស់ពួកយើងចោល។ ខ្ញុំមានអារម្មណ៍ខឹងយ៉ាងខ្លាំង តែខ្ញុំមិនអាចធ្វើអ្វីបាន។ គ្រួសាររាប់រយផ្សេងទៀតក៏ជួបនឹងបញ្ហានេះដូចគ្នានេះដែរ។ ពួកយើងបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីផ្គត់ផ្គង់ការរស់នៅ ហើយអ្នកខ្លះជំពាក់បំណុលលើសពី ១០ ០០០ដុល្លារអាមេរិកឯណោះ។"

"ដោយសារតែជំងឺរាតត្បាតកូវីដ ១៩ ពួកយើងមិនអាចរកប្រាក់គ្រប់គ្រាន់សម្រាប់សងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ត្រីកាន់តែមានចំនួនតិច ហើយពួកយើងគ្មានលទ្ធភាពផ្តល់ចំណីត្រីដើម្បីឱ្យត្រីធំធាត់។ កន្លែងចិញ្ចឹមត្រីមិនអាចសាងសង់ឡើងវិញបាន ព្រោះគ្មានប្រាក់។ អាជ្ញាធរបានជូនដំណឹងឱ្យយើងរុះរើឧបករណ៍ចិញ្ចឹមត្រីចេញពីបឹងក្នុងរយៈពេល ៦ខែ ប៉ុន្តែអាជ្ញាធរមិនបានផ្តល់ ហេតុផលណាមួយឡើយ ហើយពួកគេនឹងមិនផ្តល់សំណងឱ្យពួកយើងនោះទេ។ ពួកយើងគ្មានជម្រើស និងបានសម្រេចទៅខ្ចីប្រាក់ពីអ្នកចងការប្រាក់ដើម្បីយកទៅបង់ការប្រាក់ឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយឥឡូវនេះពួកយើងជំពាក់បំណុលកាន់តែច្រើន។ ពួកយើងចំណាយពី ៥ ០០០ ទៅ ៦ ០០០ ដុល្លារអាមេរិក សម្រាប់ទិញចំណីត្រីក្នុងមួយឆ្នាំ។ ខ្ញុំមានអារម្មណ៍ខឹង និង តក់ស្លុតដែលមិនអាចតស៊ូទាមទារសិទ្ធិរបស់ខ្ញុំជាមួយនឹងអាជ្ញាធរបាន។"

"បើសិនជាពួកគេចាក់ដីបំពេញបឹងនេះ គ្រួសារខ្ញុំ និងគ្រួសារអ្នកដទៃទៀតនឹងជួបបញ្ហាក្ស័យធន ហើយធ្លាក់ខ្លួនកាន់តែក្រីក្រ។ បើសិនជាពួកគេចាក់ដីបំពេញបឹងនេះ នោះត្រីនឹងលែងមានសម្រាប់ហូប និងយកទៅលក់នៅទីផ្សារ ដែលជាប្រភពចំណូលចម្បងសម្រាប់សហគមន៍ក្រីក្រ។ អាជ្ញាធរមិនគួរធ្វើបែបនេះចំពោះគ្រួសារក្រក្រីទាំងនេះឡើយ។ គ្រួសារទាំងនេះគ្រាន់ តែចង់មានជីវភាព និងការរស់នៅសមរម្យ ហើយទាំងអស់នេះត្រូវបានបំផ្លាញចោលដោយអាជ្ញាធរ។"



រូបភាព ទី៨៖ អាជ្ញាធរកំទេចផ្ទះសម្បែង និងកន្លែងចិញ្ចឹមត្រីរបស់ប្រជាពលរដ្ឋ

## ករណីសិក្សា ទី៣ – ជីវិតអ្នកនេសាទនៅបឹងតាមោក

“ខ្ញុំរស់នៅក្បែរបឹងតាមោករហូតដល់ឆ្នាំ ២០២០។ ខ្ញុំបានរស់នៅទីនោះអស់រយៈពេល ៥ឆ្នាំ មានមុខរបរជាអ្នកនេសាទ និងប្រើសំណាញ់ និងសន្ទូចចាប់ត្រីជារៀងរាល់ថ្ងៃ។ មុនពេលបឹងនេះត្រូវបានគេចាក់បំពេញ កត្តាជីវភាពរបស់ខ្ញុំមានភាពល្អប្រសើរ ហើយខ្ញុំអាចរកត្រីបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារខ្ញុំ។ ខ្ញុំរស់នៅក្បែរកន្លែងដែលគេចាក់ដីលុបបឹង ហេតុនេះហើយ ត្រីបានរត់ទៅតំបន់ផ្សេងនៃបឹង។ នៅពេលដែលពួកគេចាក់ដីលុបបឹង គ្រួសារខ្ញុំ ក៏ដូចជាគ្រួសារជាច្រើនផ្សេងទៀតធ្លាក់ខ្លួនក្រកាន់តែខ្លាំង ហើយខ្ញុំគ្មានលទ្ធភាពទិញអ្វីពីផ្សារបានឡើយ។ ពួកយើងទទួលបានដំណឹងផ្លូវការថាយើង កំពុងរស់នៅលើដីសាធារណៈរបស់រដ្ឋ និងត្រូវបណ្តេញចេញដើម្បីយកដីសម្រាប់សាងសង់អគារខ្ពស់ៗ។ ពួកយើងត្រូវបង្ខំ ឱ្យចាកចេញក្នុងរយៈពេលខ្លី និងមិនទទួលបានសំណង។ មុននឹងទទួលបានការជូនដំណឹងផ្លូវការ ពួកយើងព្រួយបារម្ភអំពីពាក្យចចាមអារ៉ាមដែលពួកយើងបានឮ និងឃើញគ្រឿងចាក់លុបបឹងរំកិលចូលមកកាន់តែជិតផ្ទះពួកយើង។ ពួកយើងចាប់ផ្តើមទទួលសម្ពាធបន្តិចម្តងៗពីអាជ្ញាធរឱ្យរុះរើចេញ រហូតដល់យើងសម្រេចចាកចេញ។ ខ្ញុំមិនសប្បាយចិត្តទេ ចំពោះការរើចេញនេះ ព្រោះខ្ញុំនឹកកាលរស់នៅក្បែរបឹងដែលមានបរិយាកាសល្អ និងមានកត្តាជីវភាពសមរម្យ ហើយអាចរកត្រីសម្រាប់គ្រួសារខ្ញុំហូបបាន។ ខ្ញុំមានអារម្មណ៍ភ័យខ្លាច និងបារម្ភថាមិនអាចចិញ្ចឹមគ្រួសារខ្ញុំបាន។ ខ្ញុំមិនមានពេលគ្រប់គ្រាន់សម្រាប់ តស៊ូទាមទារសិទ្ធិរបស់ខ្ញុំ ព្រោះគ្រួសារខ្ញុំមានភាពអត់ឃ្លាន និងមិនអាចរងចាំការឆ្លើយតបពីអាជ្ញាធរបានឡើយ។ ប៉ុន្តែ ខ្ញុំមិនចង់ចាកចេញពីបឹងនេះនោះទេ។”



រូបភាព ទី១០៖ អ្នកនេសាទលើបឹងតាមោក

# ៨. សេចក្តីសន្និដ្ឋាន

បច្ចុប្បន្ននេះ ក្រៅពីការកាត់ផ្ទៃបឹងដើម្បីអភិវឌ្ឍផ្សារបន្លែ បឹងនឹងជួបបញ្ហាប្រឈមផ្សេងទៀតនៅថ្ងៃអនាគត។ ឧទាហរណ៍ បឹងនឹងត្រូវបានចាក់បំពេញ ដើម្បីសាងសង់លំនៅឋាន អាគារសាធាណៈ សួនសាធារណៈ ផ្សារ ការពង្រីកដើម្បីអភិវឌ្ឍន៍ផ្នែកកសិកម្ម ចាក់ដីដើម្បីធ្វើផ្លូវកាត់បឹងដែលមានទទឹងប្រវែងជិត ៦០ម៉ែត្រ និងបណ្តោយប្រវែង ៣ ៨០០ម៉ែត្រតភ្ជាប់ពីផ្នែកម្ខាងទៅផ្នែកម្ខាងទៀតនៃបឹង។ ហើយ ដីទំហំ៥០០ ហិកតា អាចនឹងត្រូវបានកាត់ចេញបន្ថែមពីផ្ទៃបឹងនៅថ្ងៃអនាគត[៣៨] ដោយសារ យោងទៅតាមផែនការប្រើប្រាស់ដីធ្លីរបស់សាលារាជធានីភ្នំពេញ ឆ្នាំ២០៣៥ ផ្ទៃបឹងនឹងរួមមកនៅត្រឹម ២១៤០ ហិកតាប៉ុណ្ណោះ។




ផែនទី ទី២៧៖ តំបន់បឹងដែលនឹងនៅសេសសល់ក្នុងឆ្នាំ ២០៣៥

[៣៨] https://teangtnaut.org/map-layer/%e1%9e%94%e1%9e%b9%e1%9e%84%e1%9e%8f%e1%9e%b6%e1%9e%98%e1%9f%84%e1%9e%80/?lang=en

# ៩. អនុសាសន៍

យោងតាមការរកឃើញនៃរបាយការណ៍នេះ អនុសាសន៍មួយចំនួនត្រូវបានលើកឡើង៖

១. បង្ហាញជាសាធារណៈនូវបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទាំងអស់

២. ធ្វើការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីស្វែងយល់ឱ្យបានពេញលេញអំពីផលនៃការអភិវឌ្ឍនៅលើបឹង ក៏ដូចជាផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន និងប្រព័ន្ធធារាសាស្ត្រក្នុងទីក្រុង ដែលបណ្តាលមកពីការបាត់បង់បឹង។ ការសិក្សាស្រាវជ្រាវណាមួយដែលត្រូវបានធ្វើឡើង គួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដើម្បីសាធារណជន និងអ្នកជំនាញដទៃទៀតបានពិនិត្យមើល។

៣. សូមបញ្ឈប់ការអភិវឌ្ឍនានានៅលើផ្ទៃបឹងរហូតដល់មានការសិក្សាស្វែងយល់ឱ្យបានច្បាស់ទៅលើផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម។ មិនគួរមានការអភិវឌ្ឍបន្តទៀតឡើយ ប្រសិនបើបញ្ហាទាំងអស់ដែលត្រូវបានលើកឡើងនៅក្នុងការសិក្សានេះ នៅមិនទាន់ត្រូវបានស៊ើបអង្កេត ផ្សព្វផ្សាយជាសាធារណៈ និងពិភាក្សាជាមួយអ្នកតំណាងពលរដ្ឋសង្គមស៊ីវិល និងជំនាញផ្នែកបរិស្ថាន។

៤. ធ្វើការវាយតម្លៃ និងផ្សព្វផ្សាយជាសាធារណៈ អំពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម នៅលើអ៊ិនធើណេត ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាព។

៥. ប្រជាពលរដ្ឋដែលកំពុងអាស្រ័យផលពីបឹង គួរត្រូវបានអញ្ជើញឱ្យចូលរួមជាដៃគូក្នុងការប្រឹក្សាយោបល់ ជាមួយភាគីពាក់ព័ន្ធ មុនពេលតំបន់ណាមួយដែលពួកគេរស់នៅ និងប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃ ត្រូវបានសម្រេចទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។

៦. បឹងតាមោក គួរត្រូវបានអភិរក្ស ក្រោមច្បាប់ និងបញ្ញត្តិពិសេស ដែលផ្តល់នូវការការពារយ៉ាងតឹងរ៉ឹងពីការអភិវឌ្ឍ និងបំផ្លិចបំផ្លាញ ព្រោះការការពារបច្ចុប្បន្នក្រោមច្បាប់ភូមិបាល នៅមិនទាន់គ្រប់គ្រាន់នៅឡើយនោះទេ ហើយអាចបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ប្រទេសជាតិ។

៧. ធានាថាការបណ្តេញចេញ និងជម្លោះដីធ្លី ត្រូវបានដោះស្រាយដោយយោងតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្ស ស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ដែលរួមមានការផ្តល់នូវសំណងសមរម្យ និងយុត្តិធម៌។ រាជរដ្ឋាភិបាលកម្ពុជា គួរគោរពនូវកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន ដោយត្រូវគោរព ការពារ និងបំពេញនូវសិទ្ធិមនុស្សរបស់ប្រជាជនដែលរស់នៅក្នុងប្រទេសកម្ពុជា។

៨. តាមរយៈគោលនយោបាយ ច្បាប់ និងបទបញ្ញត្តិនានា រាជរដ្ឋាភិបាលត្រូវអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ក្នុងការការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សពីសំណាក់ក្រុមហ៊ុនធុរកិច្ចនានា ហើយត្រូវធានាថាក្រុមហ៊ុនឯកជនគោរពសិទ្ធិមនុស្សគ្រប់ប្រតិបត្តិការរបស់ពួកគេទាំងអស់ ដើម្បីកំណត់ បង្ការ និងកាត់បន្ថយហានិភ័យទាក់ទងនឹងសិទ្ធិមនុស្សដោយសារសកម្មភាពរបស់ពួកគេ និងទំនាក់ទំនងធុរកិច្ច ដូចមានចែងនៅក្នុងគោលការណ៍ណែនាំ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

៩. បង្ហាញព័ត៌មានផ្លូវច្បាប់នៃការជួលបឹងតាមោក និងមូលដ្ឋានផ្លូវច្បាប់ដែលបឹងតាមោកអាចផ្លាស់ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋបាន ដូចមានចែងក្នុងមាត្រា១៦នៃច្បាប់ភូមិបាលឆ្នាំ២០០១។



អង្គការសហគមន៍ធានាត្នោត

Sahmakum Teang Tnaut Organization · a Cambodian Urban NGO

ទូរស័ព្ទទំនាក់ទំនង៖ ០២៣ ៥៥៥ ១៩៦៤
គេហទំព័រ៖ **www.teangtnaut.org**
សំឡេងទីក្រុង៖ **https://urbanvoicecambodia.net**
ហ្វេសប៊ុក៖ **https://www.facebook.com/sttcambodia**